00490869

D97/16/9

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 25 / 03 / 2010
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៣៩)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក ខៀវ សំផន

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: បារាំង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គបុរេជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយរបស់សហមេធាវីការពារក្ដីលោក ខៀវ សំផន តបនឹងចម្លើយរួម របស់សហព្រះរាជអាជ្ញា លើសហខុត្រិដ្ឋកម្មរួម

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក ខៀវ សំផន**

លោក ស ស្ងាន

លោក Jacques VERGES

**ជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

កញ្ញា Annabelle REICHENBACH

**ផ្ញើរជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

00490870



សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Andrew CARLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង**

**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានតំណាង**

# សូមគោរពអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

១. ដោយអនុលោមតាមសេចក្តីសម្រេចអង្គបុរេជំនុំជម្រះចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១០[1] សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន សូមបង្ហាញនូវចម្លើយនេះដើម្បីតបទៅនឹងចម្លើយរួមរបស់សហព្រះរាជអាជ្ញាស្តីពីសហឧក្រិដ្ឋកម្មរួម[2]។

២. សហមេធាវីមេធាវីការពារក្តីសូមយោងទៅលើអំណះអំណាង ដែលខ្លួនបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន ហើយក៏សូមយោងលើអំណះអំណាងរបស់សហភាគារដើម្បីនៃក្រុមការពារក្តីដទៃទៀតផងដែរ។

## II. ការសង្ខេបបឋម

៣. ទោះបីជាសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា មានយល់ឃើញបែបណាចំពោះបញ្ហានេះក៏ដោយ ក៏សហមេធាវីការពារក្តី នៅតែបន្តរំឭកថា សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការបកប្រែនៃរាល់សេចក្តីសម្រេច និងរាល់សេចក្តីសន្និដ្ឋានទាំងអស់នៃគូភាគី ដូចដែលបានកំណត់នៅក្នុងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចនៃគូភាគីទាក់ទងការបកប្រែ និងដែលបានយល់ស្របតាមយ៉ាងច្បាស់នៅក្នុងបណ្តឹងឧទ្ធរណ៍នៃអង្គបុរេជំនុំជម្រះ និងរំឭកថាសិទ្ធិនេះត្រូវបានរំលោភជាប្រចាំ និងជានិរន្តរ៍។

៤. ជាថ្មីម្តងទៀត សហមេធាវីការពារក្តី សូមកត់សម្គាល់ថា ពួកគាត់នៅមិនតែមិនទាន់បានទទួលការបកប្រែជាភាសាបារាំងនូវសេចក្តីសន្និដ្ឋាននៃគូភាគី នៅក្នុងនីតិវិធីដែលកំពុងតែប្រព្រឹត្តទៅនេះ ដែលមានដូចតទៅ៖

---

[1] សេចក្តីសម្រេចអំពីការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីបង្គាប់ឲ្យដាក់ការឆ្លើយតប ថ្ងៃទី៩ ខែមិនា ឆ្នាំ២០១០ ឯកសារតុលាការ D97/16/6

[2] ចម្លើយរួមរបស់សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយអៀងសារី អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហឧក្រិដ្ឋកម្មរួម ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារតុលាការ D97/16/5 (តទៅនេះហៅថា ចម្លើយតប)

- សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ឯកសារតុលាការ D97/7 ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ២៨ទំព័រ។
- សារណាតបរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសហឧក្រិដ្ឋកម្មរួម ឯកសារតុលាការ D97/3/4 ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ១០ទំព័រ។
- សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ឯកសារតុលាការ D97/8 ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០៨ ២៧ទំព័រ។
- សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក អៀង សារី ទៅលើការសង្កេតបន្ថែមរបស់គាត់ទាក់ទិននឹង សហកម្មឧក្រិដ្ឋកម្មរួម ដាក់នៅថ្ងៃទី២៤ ខែវិច្ឆិកា ២០០៨៖ កម្រិតត្រឹមតែសេចក្តីសម្រេច របស់មហាសន្និបាតអង្គការសហប្រជាជាតិដែលអាចអនុវត្តបាន ដែលបានអះអាង/ដកចេញ ដោយ ក.ស.ព ឯកសារតុលាការ D97/12 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៩ ២៧ទំព័រ។
- បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថា ជាសហឧក្រិដ្ឋកម្មរួម ឯកសារតុលាការ D97/14/5 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ៤១ ទំព័រ។
- បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ចំពោះ "ដីកាសម្រេចអំពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថា ជាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារតុលាការ D97/15/1 ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ២៦ ទំព័រ។

៥. ស្ថានភាពនេះផ្ទុយទៅនឹងច្បាប់អនុវត្ត សមធម៌ និងសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការចូលរួមឲ្យបានពេញលេញទៅនឹងនីតិវិធី។ សហមេធាវីមេធាវីការពារក្តីសូមលោកចៅក្រមនៃអង្គបុរេជំនុំជម្រះមេត្តាទទួលស្គាល់បញ្ហាខាងលើនេះ។

## II. អំណះអំណាង

### ក. បណ្តឹងឧទ្ធរណ៍មានលក្ខណៈអាចទទួលយកបាន

៦. ផ្ទុយទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញា ហើយដូចដែលឈ្មោះរបស់វាបានបញ្ជាក់ស្រាប់ ដីកាសម្រេចស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់ទទួលខុសត្រូវដែលហៅថា "សហឧក្រិដ្ឋកម្មរួម" មិនមែនជាសេចក្តីប្រកាសជាសាមញ្ញនោះឡើយ តែជាដីកាសម្រេច។ ដីកាសម្រេចនោះមានផលវិបាកជាក់ស្តែងដែលផ្តល់សមត្ថកិច្ចដល់ អ.វ.ត.ក លើទម្រង់នៃការទទួលខុសត្រូវថ្មីមួយ។

៧. តាមពិតទៅ ហើយដូចមានគូសបញ្ជាក់នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍មេធាវីការពារក្តីដូចោះដែរ[3] ជាការជាក់ច្បាស់ណាស់ដែលថាពាក្យបណ្តឹងរបស់លោក អៀង សារីដែលសុំឱ្យអង្គបុរេជំនុំជម្រះ ពិនិត្យមើលថា ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដូចមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.កឡើយ[4] វាត្រូវចាត់បញ្ចូលជាបណ្តឹងជំទាស់យុត្តាធិការ ដែលលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត ក្នុងក្របខណ្ឌនៃវិធានផ្ទៃក្នុង ៥៥ (១០) និងវិធាន ៥៣ (១)។

៨. វាជាក់ច្បាស់ណាស់ដែលថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត គឺពិតជា "ដីកាសម្រេចដែលទទួលស្គាល់នូវសមត្ថកិច្ចរបស់អ.វ.ត.ក" តាមវិធាន ៧៤ (៣) នៃវិធានផ្ទៃក្នុង។ រីឯចម្លើយរបស់សហព្រះរាជអាជ្ញាផ្ទាល់ គឺជាតឹកតាងបញ្ជាក់ស្រាប់។ តាមពិតទៅ ៖

- នៅក្នុងចម្លើយរួមរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងពី "អង្គហេតុ" ទាក់ទិនទៅនឹងសហឧក្រិដ្ឋកម្មរួម ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបអង្កេតតាំងពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរម្ល៉េះ។[5] តាមរយៈអំណះអំណាងនេះ គេកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាសុខចិត្តទទួលយកជំហររបស់មេធាវីការពារក្តី ដែលយល់ថា ការកំណត់យកសហកម្មឧក្រិដ្ឋកម្មរួមអាចមានផលវិបាកជាក់ស្តែងទៅលើការស៊ើបអង្កេត និងក្នុងការជូនដំណឹងអំពីបទចោទប្រកាន់។

---

[3] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់ឱ្យអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលហៅថា "សហឧក្រិដ្ឋកម្មរួម" ថ្ងៃទី៨ ខែមករា ឆ្នាំ២០១០ ឯកសារតុលាការ D97/16/1 កថាខណ្ឌ ២៩ ដល់ ៣៣

[4] ពាក្យស្នើសុំរបស់លោកអៀង សារីប្រឆាំងទៅនឹងការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម ឯកសារតុលាការ D97

[5] ចម្លើយតប កថាខណ្ឌទី៨។

- លើសពីនោះទៀត និងផ្ទុយពីអ្វីដែលសហព្រះរាជអាជ្ញាអះអាង ទម្រង់នៃការទទួលខុសត្រូវនេះ គឺជាការចោទប្រកាន់ថ្មី ព្រោះវានាំឲ្យមានជាការដាក់ឲ្យស្ថិតក្រោមការពិនិត្យថ្មីមួយទៀតទៅលើ លោក ខៀវ សំផន។[6]

៩. ផ្ទុយទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាបានគាំទ្រ ការសម្រេចថា ត្រូវយកទម្រង់នៃការទទួលខុសត្រូវដែលជាសហឧក្រិដ្ឋកម្មរួមមកអនុវត្តចំពោះមុខអ.វ.ត.ក ពិតជាមានផលវិបាកជាក់ស្តែងចំពោះជនត្រូវចោទទាំងឡាយ ហើយវាមានសភាពបែបនោះតាំងពីការស៊ើបសួរម្ល៉េះ ហើយការទាត់ចោលបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ដោយគ្មានការពិនិត្យឲ្យបានស៊ីជម្រៅ វាផ្ទុយទៅនឹងសិទ្ធិក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ ដែលមានចែងនៅក្នុងវិធាន ២១។

១០. គ្មាននរណាម្នាក់បានបដិសេធថាទម្រង់នៃការទទួលខុសត្រូវ ដែលជាសហឧក្រិដ្ឋកម្មរួមនោះ ជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដ៏ធំធេងឡើយ។ សហព្រះរាជអាជ្ញាអះអាងថា "ដើមបណ្តឹងឧទ្ធរណ៍អាចនឹងមិនត្រូវរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌមួយឬច្រើន ទាក់ទងនឹងការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមនោះទេ។ ក្នុងស្ថានភាពនេះ ការអនុវត្តក្នុងពេលបច្ចុប្បន្ន គឺគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ"។[7] សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា "ដើមបណ្តឹងឧទ្ធរណ៍នឹងនៅតែមានមូលហេតុដែលមានសុពលភាព ដើម្បីដាក់បណ្តឹងជំទាស់យុត្តាធិការទៅអង្គជំនុំជម្រះ"។[8]

១១. ផ្ទុយទៅវិញ មេធាវីការពារក្តីសូមអះអាងថា ការជម្រះក្តីអាចនឹងពុំកើតមានឡើង ហើយការស៊ើបអង្កេតអាចជាវគ្គបញ្ចប់នៃនីតិវិធីនេះ។ មេធាវីការពារក្តីអះអាងទៀតថា ជនត្រូវចោទមានសិទ្ធិទទួលបានដីកាលើកលែងការចោទប្រកាន់ ចំពោះអង្គហេតុដែលមិនអាចអោយមានការដាក់ទោសទណ្ឌបាន ហើយក៏អះអាងទៀតថា ការធានានូវសិទ្ធិមួយចំនួនរបស់គាត់ ដោយបញ្ជូនពួកគាត់ទៅទទួលការជម្រះក្តី ដោយឈរលើមូលដ្ឋាននៃបទចោទប្រកាន់ដែលមិនមានពិតនោះ គឺមិនមែនមានន័យថា ជាការធានាដល់ពួកគាត់ក្នុងការទទួលបាននូវការកាត់ក្តីប្រកបដោយយុត្តិធម៌ឡើយ។

១២. ប្រសិនបើសេចក្តីប្រកាសនៃសហចៅក្រមស៊ើបអង្កេតពុំមានឥទ្ធិពលអ្វីទៅលើសិទ្ធិនានា និងនីតិវិធីទេនោះ

---

[6] កំណត់ហេតុនៃការសួរចម្លើយលោកខៀវ សំផន ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារតុលាការ D285 កថាខណ្ឌទី៩។

[7] ចម្លើយតប កថាខណ្ឌទី១៥។

[8] ចម្លើយតប កថាខណ្ឌទី១៦។

តើហេតុដូចម្ដេចបានជាវាបង្កឱ្យមានការប៉ះទង្គិចខ្លាំងក្លាយ៉ាងនេះ ពីសំណាក់ការិយាល័យសហព្រះរាជអាជ្ញា ដែលបានដាក់អំណះអំណាងមិនតិចជាង១០០ទំព័រ ដើម្បីការពារការអនុវត្តសហឧក្រិដ្ឋកម្មរួមចំពោះមុខ អ.វ.ត.ក ?

១៣. តាមពិតទៅ និងដោយសុំកុំឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចសេចក្ដី ដោយអះអាងថា "អង្គបុរេជំនុំជម្រះ *មិនគួរចេញលិខិតស្នើសុំនោះឡើយ ព្រោះនៅមានអង្គយុត្តិធម៌ផ្សេងមួយទៀត (គឺសាលាដំបូង) ដែលអាចទទួលយកសំណុំរឿងនេះបានប្រសើរជាង* (...)" សហព្រះរាជអាជ្ញាសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធតួនាទីខ្លួនជាសាលាឧទ្ធរណ៍នៃការស៊ើបអង្កេត ដោយទុកឱ្យសហចៅក្រមស៊ើបអង្កេត ជាអ្នកចាត់ចែងតែឯងទៅលើចំណោទដ៏សំខាន់នេះ។ អំណះអំណាងដែលលើកឡើងពីការសន្សំសំចៃសម្រាប់តុលាការ គឺមិនសមហេតុផល មិនអាចទទួលយកបាន ហើយនិងមិនអាចនាំឱ្យជឿនលឿនទៅមុខបានឡើយ។

## ខ. បណ្ដឹងឧទ្ធរណ៍មានមូលដ្ឋានគ្រឹះត្រឹមត្រូវ

១៤. មេធាវីការពារក្ដីសង្កេតឃើញថា សហព្រះរាជអាជ្ញាមិនបានឆ្លើយតបនឹងអំណះអំណាងរបស់ខ្លួនទៅលើខ្លឹមសារឡើយ ហើយបានត្រឹមតែឆ្លើយទៅនឹងអំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី តែប៉ុណ្ណោះ។ ដើម្បីធានាបាននូវការវិភាគអំណះអំណាងឱ្យបានគ្រប់ជ្រុងជ្រោយ មេធាវីការពារក្ដីសូមរំឭកពីអំណះអំណាងសំខាន់ៗ ដូចបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។

### ១) សហឧក្រិដ្ឋកម្មរួមមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ

១៥. ការចាត់ទុកថា សហឧក្រិដ្ឋកម្មរួមអាចប្រើប្រាស់ជាមូលដ្ឋានគ្រឹះដើម្បីបង្ក្រាបព្រឹត្តិការណ៍ដែលកើតមានចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ មានន័យថាជាការមាក់ងាយដល់គោលការណ៍នីត្យានុកូលភាព និងផលវិបាករបស់វា គោលការណ៍នៃការបកស្រាយយ៉ាងម៉ត់ចត់ និងគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺមានន័យថា ភ្លេចគិតថាមានតែការទទួលខុសត្រូវបុគ្គលទេ ដែលជាការទទួលខុសត្រូវព្រហ្មទណ្ឌ និងជាការធ្វើមិនដឹងថាក្នុងករណីសង្ស័យ គឺបទដ្ឋានដែលផ្ដល់ភាពអនុគ្រោះបំផុតដែលត្រូវយកមកអនុវត្ត ពោលគឺតាមគោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ(*in dubio pro reo*)។

១៦. ការអនុវត្តទម្រង់ដែលមិនច្បាស់លាស់ និងមិនផ្ទាល់នេះមិនគោរពទាំងស្មារតី និងអត្ថរូបនៃច្បាប់ និងសេចក្តីព្រមព្រៀងស្តីពី អ.វ.ត.ក ហើយឆ្ពោះទៅរកយុត្តិសាស្ត្រនៃតុលាការបណ្តោះអាសន្ន (Les Tribunaux ad-hoc) ឱ្យទៅជាបទដ្ឋានយោង សម្រាប់កំណត់ឋានានុក្រមក្នុងបទដ្ឋានគតិយុត្តិនៅកម្ពុជា ហើយទាំងនោះ ពុំមានអ្វីជាទីសំអាងឡើយ។

**២) ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបង្កើតប្រព័ន្ធបង្ក្រាបបទល្មើសឱ្យមានល្បឿនពីរ**

> *មានរបបគតិយុត្តិតែមួយគត់ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦*

១៧. ក្នុងដីកាសម្រេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានចាត់ទុកថា *"ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ យកគំរូតាមច្បាប់បារាំង ហើយក្នុងច្បាប់បារាំងនេះ ឧក្រិដ្ឋកម្មអន្តរជាតិ ដូចជា ឧក្រិដ្ឋកម្មអន្តរជាតិដែលស្ថិតក្នុងសមត្ថកិច្ចយុត្តាធិការរបស់អ.វ.ត.ក គឺជាឧក្រិដ្ឋកម្មដែលមានលក្ខណៈពិសេស ស្ថិតក្នុងរបបគតិយុត្តិពិសេសដាច់ដោយឡែកមួយផ្សេងពីច្បាប់ព្រហ្មទណ្ឌជាតិ និងត្រូវបានសម្គាល់ដោយចរិតលក្ខណៈពិសេសនៃវិធាននីតិវិធី និងច្បាប់"*។[9]

១៨. ក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេត បានបង្ហាញយ៉ាងជាក់ច្បាស់ថា ក្រមព្រហ្មទណ្ឌនៃឆ្នាំ១៩៥៦ គឺជាបទដ្ឋានយោង ដើម្បីកំណត់នូវទម្រង់ទទួលខុសត្រូវដែលអាចអនុវត្តបាននៅក្នុងខណៈដែលបទឧក្រិដ្ឋទាំងនោះកំពុងតែប្រព្រឹត្តទៅ ហើយសព្វថ្ងៃអាចដាក់ទោសបាន។[10]

១៩. ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតទៅលើច្បាប់នេះ និងការប្រៀបធៀបរបស់ពួកគាត់ទៅនឹងច្បាប់បារាំងគឺពិតជាខុសទាំងស្រុង។ ការប្រៀបធៀបទៅនឹងច្បាប់បារាំងនាំឱ្យមានសេចក្តីសន្និដ្ឋានបែបផ្សេងទៅវិញ។ តាមពិត គ្មានរបបគតិយុត្តិពិសេសណាមួយសម្រាប់តែឧក្រិដ្ឋកម្មអន្តរជាតិឡើយ ទាំងនៅក្នុងច្បាប់កម្ពុជា ក៏ដូចជាច្បាប់បារាំងកាលពីសម័យកាលនោះ។

២០. នៅក្នុងច្បាប់ព្រហ្មទណ្ឌបារាំង មុននឹងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៩៤ បានចូលជាធរមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនទាន់ទាំងមាន ក្នុងនាមជាបទល្មើសស្វ័យតនៅឡើយទេ ហើយ "ដូច្នេះជាឧទាហរណ៍

---

[9] ដីកាសម្រេច កថាខណ្ឌ ២២

[10] ចំពោះចំណុចនេះ សូមអានអំណះអំណាងដែលលើកឡើងនៅក្នុងសារណាផ្សេងៗរបស់លោក អៀង សារី

គេពុំអាចនឹងលើកឡើងពីអំពើដែលបានប្រព្រឹត្តនៅអំឡុងសង្គ្រាមឥណ្ឌូចិនឡើយ”[11]។ បន្ទាប់ពីក្រមព្រហ្មទណ្ឌឆ្នាំ ១៩៩៤ បានចូលជាធរមាន “ដោយសារតែច្បាប់ថ្មីមានលក្ខណៈតឹងរ៉ឹងជាងច្បាប់ចាស់ (...) បទប្បញ្ញត្តិកន្លងមកដែលតុលាការកំពូលបានកំណត់អនុវត្ត[12] នៅតែអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ និងចំពោះតែឧក្រិដ្ឋកម្មទាំងនោះតែប៉ុណ្ណោះ”[13]។

២១. ដូច្នេះ យើងស្ថិតឆ្ងាយណាស់ពីរបបគតិយុត្តិពិសេសនៃឧក្រិដ្ឋកម្មអន្តរជាតិ ដែលកំណត់ទុកជាមុននូវទម្រង់នៃការទទួលខុសត្រូវដែលមិនមាន និងដែលអាចអនុវត្តបានចំពោះតែបទល្មើសទាំងនោះតែប៉ុណ្ណោះ។

> ➢ *ការបកស្រាយនូវមាត្រា ២៩ ត្រូវតែមានលក្ខណៈតែមួយ និងត្រូវបកស្រាយដើម្បីផ្តល់អត្ថប្រយោជន៍ដល់ជនត្រូវចោទ*

២២. សហចៅក្រមស៊ើបអង្កេតចាត់ទុកថា *“ដោយអនុលោមទៅតាមគោលការណ៍បកស្រាយរបបគតិយុត្តិពិសេស ស្របទៅតាមច្បាប់ប្រទេសបារាំង ទម្រង់នៃការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មអន្តរជាតិអាចត្រូវបានអនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ។”* [14]

២៣. តាមពិតទៅ ពុំមានរបបគតិយុត្តិពិសេសឧក្រិដ្ឋកម្មអន្តរជាតិឯណាលើសពីគោលការណ៍នៃការបកស្រាយផ្ទាល់ចំពោះរបបគតិយុត្តិនោះឡើយ។ ដូច្នេះពុំមែនជារបបគតិយុត្តិពីរដែលប្រឆាំងតបគ្នានោះឡើយ តែជាការវិភាគគតិយុត្តិផ្ទុយគ្នាពីរដែលកំណត់លើពាក្យតែមួយ៖ ក្នុងករណីមួយពាក្យថា“ប្រព្រឹត្ត” និយាយពីការបញ្ចេញសកម្មភាពរួមគ្នា នៅក្នុងករណីមួយទៀត ពាក្យដដែលនេះនិយាយពីសហឧក្រិដ្ឋកម្មរួម។

---

[11] DESPORTES (F.), LE GUNEHEC (F.) ច្បាប់ព្រហ្មទណ្ឌទូទៅ គ្រឹះស្ថានរៀបរៀង Economica ប៉ារីស៍ ឆ្នាំ២០០២ កថាខណ្ឌទី១៧៧ និង១៧៨

[12] បទប្បញ្ញត្តិស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

[13] DESPORTES (F.), LE GUNEHEC (F.) ច្បាប់ព្រហ្មទណ្ឌទូទៅ គ្រឹះស្ថានរៀបរៀង Economica ប៉ារីស៍ ឆ្នាំ២០០២ កថាខណ្ឌទី១៧៧ និង១៧៨

[14] ដីកាសម្រេចស្តីពីការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ឯកសារតុលាការ D97/13 ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌទី២២

២៤. វាជាការច្បាស់ណាស់ដែលថា "នៅក្នុងប្រព័ន្ធគតិយុត្តិតែមួយ មានតែទ្រឹស្តីតែមួយក្នុងចំណោមទ្រឹស្តីទាំងពីរដែលត្រូវមានប្រៀបជាងគេ"[15]។ ដោយដឹងថាសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា សហឧក្រិដ្ឋកម្មរួមមិនអាចយកមកអនុវត្តសម្រាប់ឧក្រិដ្ឋកម្មថ្នាក់ជាតិ ដូច្នេះ គេមិនអាចចាត់ទុកទៀតថា សហឧក្រិដ្ឋកម្មរួម អាចជាទ្រឹស្តីតែមួយដែលមានប្រៀបជាងនៅចំពោះមុខអ.វ.ត.កទៀតឡើយ។

២៥. មាត្រា ១២ នៃសេចក្តីព្រមព្រៀងបានចែងថា ច្បាប់អន្តរជាតិអាចយកមកប្រើប្រាស់ជាឯកសារយោងក្នុងករណីដែលច្បាប់កម្ពុជាមិនមានចែងអ្វីត្រង់ចំណុចនោះ។ ម្យ៉ាងទៀត ដោយផ្អែកទៅលើមូលដ្ឋាននេះ ហើយដែលសហចៅក្រមស៊ើបអង្កេតបានចាត់ទុកថា អ.វ.ត.ក ត្រូវបានចាត់ទុកជាតុលាការអន្តរជាតិ។ នៅក្នុងច្បាប់អន្តរជាតិ វិធានស្តីពីការបកស្រាយច្បាប់តម្រូវឱ្យចៅក្រមគោរពតាមគោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo) ឱ្យបានត្រឹមត្រូវ ដែលកំណត់ថា ក្នុងករណីមានការសង្ស័យលើការបកស្រាយទៅលើអត្ថបទច្បាប់ គឺការសង្ស័យនោះត្រូវផ្តល់ជាប្រយោជន៍ដល់ជនត្រូវចោទ។

២៦. គោលការណ៍នៃច្បាប់អន្តរជាតិនេះត្រូវតែយកមកអនុវត្ត ដើម្បីបកស្រាយអត្ថបទគតិយុត្តិដែលកំណត់អំពីទម្រង់នៃការទទួលខុសត្រូវ ដែលយកមកអនុវត្តចំពោះជនត្រូវចោទនៅ អ.វ.ត.ក។ ក្នុងករណីនេះ ទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួមមានភាពតឹងរ៉ឹងជាងសកម្មភាពរួម ដូច្នេះ គឺការបកស្រាយទីពីរនេះហើយដែលត្រូវមានប្រៀបជាង។

## II. អាស្រ័យហេតុនេះ

២៧. មេធាវីការពារក្តីរបស់លោក ខៀវ សំផន សូមអង្គបុរេជំនុំជម្រះមេត្តា ៖

- **ទទួលស្គាល់** លើការរំលោភទៅលើសិទ្ធិការពារក្តីរបស់លោក ខៀវ សំផន ក្នុងនីតិវិធីទាំងមូលដែលទាក់ទិននឹងសហកម្មឧក្រិដ្ឋកម្មរួម
- **ទទួលស្គាល់** ថាដីកាសម្រេចមានភាពយឺតយ៉ាវដែលជាការរំលោភទៅលើវិធាននៃការកាត់ក្តីប្រកបដោយយុត្តិធម៌។

[15] Sylvestre Gacumbitsi តទល់នឹងរដ្ឋអាជ្ញា ថ្ងៃទី៧ ខែកក្កដាឆ្នាំ២០០៦ មតិមិនយល់ស្របរបស់ចៅក្រម Shahabuddeen, កថាខណ្ឌទី៥០

- **លុបចោល** ដីកាសម្រេចលើរាល់បទប្បញ្ញត្តិទាំងអស់។
- **ប្រកាស** ថា អ.វ.ត.កពុំមានសមត្ថកិច្ចក្នុងការបន្តវិនិច្ឆ័យជនត្រូវចោទ ដោយឈរលើទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម និង**បង្គាប់** ឲ្យលុបចោលបទចោទប្រកាន់ទាំងនេះដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

**រក្សាសិទ្ធិកែប្រែគ្រប់បែបយ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី **ស សុខាន**<br>មេធាវី **Jacques VERGÈS** | ភ្នំពេញ<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |